CAMBREW LTD

Part of the Carlsberg Group

# អភិវឌ្ឍឲ្យកាន់តែប្រសើរ

# ថ្ងៃនេះ ៥ ស្អែក






# កិច្ចប្រជុំថ្នាក់ដឹកនាំខេមប្រ៊ូវ នានិទាឃរដូវ ២០២៣ ដើម្បីរៀបចំយុទ្ធសាស្ត្រអាជីវកម្មជម្នះបញ្ហាប្រឈម



កិច្ចប្រជុំផែនការយុទ្ធសាស្ត្រលើកទីមួយក្នុងឆ្នាំ២០២៣ របស់ខេមប្រ៊ូវ ត្រូវបានរៀបចំឡើងរយៈពេល២ថ្ងៃ គឺនៅថ្ងៃទី២០-២១ ខែកុម្ភៈ នៅរមណីយដ្ឋានវីគីរីរម្យ ខេត្តកំពង់ស្ពឺ។
ថ្នាក់ដឹកនាំដែលចូលរួម បានដឹងត្រួសៗពីគោលបំណង និងសកម្មភាពដែលត្រូវធ្វើក្នុងពេលកិច្ចប្រជុំ ប៉ុន្តែពួកយើងបានចាប់ផ្តើមជាមួយនឹងក្រដាសទទេស្អាត នៅពេលដែលប្រមូលធាតុចូល និងគំនិតយោបល់ផ្សេងៗ ដើម្បីបង្កើតផែនការយុទ្ធសាស្ត្រអាជីវកម្មរបស់យើង។
កិច្ចប្រជុំនេះ មិនត្រឹមតែមានគោលបំណងពិភាក្សា ប្រមូលធាតុចូល និងការបង្កើតផែនការយុទ្ធសាស្ត្រអាជីវកម្មសម្រាប់ឆ្នាំ២០២៣ប៉ុណ្ណោះទេ តែក៏ពិនិត្យ និងជ្រើសរើស អ្នកដឹកនាំក្រឡាចត្រង្គទាំង៩ សម្រាប់ឆ្នាំ២០២៣។ កិច្ចប្រជុំនេះ ចាត់ទុកជាជាជំហានដំបូង ក្នុងការពង្រឹងគ្រប់ចំណុចដែលពាក់ព័ន្ធនឹងការរៀបចំបង្កើតផែនការយុទ្ធសាស្ត្ររបស់ខេមប្រ៊ូវ។














ការសម្រេចនានាដែលបានធ្វើនៅក្នុងកំឡុងពេលកិច្ចប្រជុំ នឹងក្លាយជាធាតុចូលដ៏សំខាន់នៅក្នុងការកំណត់ និង សម្រួចការអនុវត្តផែនការយុទ្ធសាស្ត្ររបស់យើងសម្រាប់ប្រាំទៅប្រាំមួយខែខាងមុខនេះ និង ផ្តោតលើការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងដោយយកចិត្តទុកដាក់។

ក្នុងស្មារតីអភិវឌ្ឍន៍រួមគ្នា យើងប្តេជ្ញាអនុវត្តយុទ្ធសាស្ត្រដែលបានឯកភាពជាមួយគ្នា ឱ្យកាន់តែមានប្រសិទ្ធភាពជាមួយនឹងការតាំងចិត្តខ្ពស់ ជម្នះឧបសគ្គ ដើម្បីសម្រេចតាមយុទ្ធសាស្ត្រ SAIL’27 ។




# អគ្គនាយកគ្រប់គ្រង ចែករំលែកពីជោគជ័យរបស់ខេមប្រ៊ូវ នៅក្នុងជំនួបដៃគូចែកចាយប្រចាំឆ្នាំ








អគ្គនាយកគ្រប់គ្រងខេមប្រ៊ូវ Vladimir បានសាទរភាពជោគជ័យរបស់ក្រុមហ៊ុន នៅក្នុងសន្និសីទតំណាងចែកចាយប្រចាំឆ្នាំលើកទី៣ រាប់ចាប់តាំងពីខេមប្រ៊ូវ ក្លាយជាបុត្រសម្ព័ន្ធមួយរបស់ កាសស្បឺរ គ្រុប។ នេះ ជាសន្និសីទដ៏សំខាន់មួយសម្រាប់ខេមប្រ៊ូវ ព្រោះថាយើងបានជួបប្រជុំជាមួយដៃគូអាជីវកម្មតំណាងចែកចាយមកពីទូទាំងប្រទេស ដើម្បីពិភាក្សាអំពីបទពិសោធន៍ និងលទ្ធផលឆ្នាំ២០២២ ក៏ដូចជាប្រមូលធាតុចូល ដើម្បីកំណត់គោលដៅឆ្នាំថ្មីឆ្នាំ២០២៣ និងពិភាក្សារៀបចំផែនការយុទ្ធសាស្ត្រអាជីវកម្ម ក៏ដូចជាបញ្ហាប្រឈម និងការជួយគាំទ្រនានាពីខេមប្រ៊ូវ ដើម្បីជំរុញឱ្យអាជីវកម្ម និងកិច្ចសហការរបស់ពួកយើងកាន់តែរីកចម្រើនប្រកបដោយចីរភាព និងមានស្ថិរភាពរឹងមាំ។







ការណ៍នេះ Vlad អគ្គនាយករបស់យើងក៏បានចែករំលែកគន្លឹះ និងគោលដៅសំខាន់ៗ ដើម្បីប្រយុទ្ធក្នុងទីផ្សារដ៏ប្រកួតប្រជែង។ Vlad ក៏បានគូសរៀបរាប់ពីវឌ្ឍនភាពដ៏ប្រសើរ របស់អាជីវកម្មយើងនៅក្នុងឆ្នាំ២០២២ ដោយភេសជ្ជៈបង្កើនថាមពល ស្ទីង នៅរក្សាបានភាពខ្លាំងនៅក្នុងទីផ្សារ ប៉ុន្តែលោកក៏បានបញ្ជាក់ថា យើងត្រូវបន្តជំរុញកំណើនរបស់ស្រាបៀរដ៏ល្អឥតខ្ចោះរបស់យើង ដែលគួរនាំមុខដោយ ស្រាបៀរកាសស្បឺរ ហ្គីនេស និងស្រាបៀរសិង្ហ។
តាមស្ថានភាពអាជីវកម្មបច្ចុប្បន្ន និងកិច្ចសហប្រតិបត្តិការជាមួយតំណាងចែកចាយ យើងត្រូវពង្រឹង និងពង្រីកសក្តានុពលនៃពាណិជ្ជសញ្ញាផលិតផលរបស់យើង ទៅតាមតំបន់ដែលជាគោលដៅជាមួយនឹងការអនុវត្តយុទ្ធសាស្ត្រផ្សេងគ្នា។



ទន្ទឹមនឹងនេះ ខេមប្រ៊ូវ ក៏បានអភិវឌ្ឍ និងចាប់ផ្តើមយុទ្ធសាស្ត្រគន្លឹះជាច្រើន ហើយបានរៀបចំឱ្យមានក្រុមការងារជំនាញ ចុះជួយគាំទ្រដល់ដៃគូតំណាងចែកចាយរបស់យើងតាមតំបន់នីមួយៗ ដើម្បីឱ្យអាជីវកម្មរបស់យើងមានប្រៀបជាងគេ នៅក្នុងទីផ្សារដ៏ប្រកួតប្រជែងនេះ។ ជាមួយគ្នានេះ ប្រធានគ្រប់គ្រងផ្នែកលក់ប្រចាំភូមិភាគនីមួយៗ ក៏បានត្រៀមខ្លួនរួចជាស្រេច ក្នុងការផ្តល់យុទ្ធសាស្ត្រលក់ដល់ដៃគូតំណាងចែកចាយរបស់យើងផងដែរ។

















នៅក្នុងសន្និសីទដ៏អធិកអធមនេះ យើងក៏បានរៀបចំកិច្ចថ្លែងអំណរគុណដល់ដៃគូអាជីវកម្មទាំងអស់ ទាំងដៃគូថ្មី និងដៃគូយូរអង្វែងដែលបានរួមដំណើរជាមួយយើងអស់រយៈពេលជាង ២៥ ឆ្នាំមកហើយ ហើយយើងក៏បានប្រកាសពីដៃគូអាជីវកម្មឆ្នើមបំផុតប្រចាំឆ្នាំ២០២២ ព្រមជាមួយនឹងការប្រគល់សាច់ប្រាក់ និងកញ្ចប់ដំណើរកម្សាន្តនៅអឺរ៉ុបជារង្វាន់លើកទឹកចិត្តសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់ពួកគាត់។

កម្មវិធីនេះ បានបញ្ចប់ទៅដោយរលូនពោរពេញដោយផ្លែផ្កា និងបានបិទបញ្ចប់ដោយពិធីជប់លៀងពេលរាត្រីជាមួយគ្នា ដែលជាឱកាសឱ្យក្រុមការងារពាក់ព័ន្ធរបស់ខេមប្រ៊ូវ បានកសាងទំនាក់ទំនងជាមួយដៃគូអាជីវកម្មកាន់តែជិតស្និទ្ធ។

សន្និសីទនេះ ជាកិច្ចប្រជុំដ៏មានសារៈសំខាន់មួយ ដែលយើងបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្រ្តអាជីវកម្មស្នូលរបស់យើង។






# ខេមប្រ៊ូវ បាន ក្លាយជាអង្គភាព ឆ្នើមមួយក្នុង យុទ្ធនាការ កម្ពុជាស្អាត ឆ្នាំ២០២២


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

លេខៈ..........

វិញ្ញាបនបត្រទទួលស្គាល់

ក្រុមហ៊ុន ស្រាបៀរកម្ពុជាខេមប្រ៊ូវ

បានចូលរួមយ៉ាងសកម្មក្នុងយុទ្ធនាការ កម្ពុជាស្អាត កម្ពុជាបៃតង
និងត្រូវបានទទួលស្គាល់ថា អង្គភាពឆ្នើម ក្នុងយុទ្ធនាការកម្ពុជាស្អាត

(CLEAN CITY HERO)

2022

ថ្ងៃ..........ខែ..........ឆ្នាំ..........ស័ក ព.ស២៥..
រាជធានីភ្នំពេញ, ថ្ងៃទី.....ខែ..........ឆ្នាំ២០..

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
ប្រធាន

ថោង ខុន
រដ្ឋមន្ត្រីក្រសួងទេសចរណ៍

កម្ពុជា ស្អាត
CLEAN CITY HERO




ខេមប្រ៊ូវ ដែលជាក្រុមហ៊ុនផលិតស្រាបៀរធំជាងគេមួយនៅក្នុងកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងយុទ្ធនាការកម្ពុជាស្អាត កម្ពុជាបៃតង ឆ្នាំ២០២២ ហើយជាលទ្ធផល យើងក៏ត្រូវបានទទួលស្គាល់ថាជា អង្គភាពឆ្នើមមួយក្នុងយុទ្ធនាការនេះសម្រាប់ឆ្នាំ២០២២ ពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។




វិញ្ញាបនបត្រទទួលស្គាល់នេះ ត្រូវបានប្រគល់ជូនដោយផ្ទាល់ពីឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ នាឱកាសនៃទិវាជាតិទីក្រុងស្អាតលើកទី១១ ឆ្នាំ២០២៣ ដែលរៀបចំឡើងក្រោមប្រធានបទ «ទីក្រុងស្អាត បដិសណ្ឋារកិច្ចល្អ ម្ចាស់ផ្ទះកម្ពុជាផ្តល់ភាពកក់ក្តៅ» និងពិធីប្រកាសជ័យលាភីទីក្រុងស្អាតលើកទី៣ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣។ ខុសពីឆ្នាំមុនៗ យុទ្ធនាការទីក្រុងស្អាតឆ្នាំនេះ បានពង្រីកការទទួលស្គាល់របស់ខ្លួនដល់វិស័យឯកជន និងអង្គការស្ថាប័ន ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងការលើកកម្ពស់អនាម័យ បរិស្ថាន និងសោភ័ណភាពទីក្រុង ហើយខេមប្រ៊ូវ ជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនតែពីរប៉ុណ្ណោះ ដែលទទួលបានវិញ្ញាបនបត្រទទួលស្គាល់ជាអង្គភាពឆ្នើមក្នុងយុទ្ធនាការកម្ពុជាស្អាត ឆ្នាំ២០២២។ ខេមប្រ៊ូវ បន្តប្តេជ្ញាចូលរួមឱ្យកាន់តែសកម្មក្នុងយុទ្ធនាការទីក្រុងស្អាត កម្ពុជាបៃតង តាមរយៈការលើកកម្ពស់អនាម័យ បរិស្ថាន និងការរស់នៅស្អាត ហើយក៏សង្ឃឹមថា យើងនឹងទទួលបាននូវការទទួលស្គាល់ថ្មីទៀតនៅក្នុងឆ្នាំ២០២៣នេះ។




# ពានរង្វាន់ និងបណ្ណសរសើររបស់យើង ក្នុងឆ្នាំ២០២២

ក្នុងនាមជាបុត្រសម្ព័ន្ធមួយរបស់ កាសស្បឺរ គ្រុប ខេមប៊្រូវ មានមោទកភាព ដែលបានសម្រេចនូវសមិទ្ធផលសំខាន់ៗមួយចំនួន នៅក្នុងឆ្នាំ២០២២។ យើងនៅតែរក្សាបាននូវកិត្តិនាម និងកេរ្តិ៍ឈ្មោះដ៏ល្អ ក្នុងនាមជាប្រតិបត្តិករដែលមានទំនួលខុសត្រូវខ្ពស់ ក៏ដូចជាសកម្មបំផុតមួយក្នុងការចូលរួមចំណែកជួយអភិវឌ្ឍសង្គម ហើយពាណិជ្ជសញ្ញាផលិតផលរបស់យើង នៅតែរក្សាបាននូវភាពឈានមុខគេនៅក្នុងទីផ្សារ។

ក្នុងឆ្នាំ២០២២ យើងទទួលបានពានរង្វាន់ និងបណ្ណសរសើរជាច្រើន ពីស្ថាប័នជាតិ និងអន្តរជាតិ ដែលនេះជាតឹកតាងសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន ក្នុងការដឹកនាំប្រតិបត្តិការអាជីវកម្មប្រកបដោយការទទួលខុសត្រូវ និងចូលរួមចំណែកដើម្បីសង្គមកាន់តែប្រសើរ។




ពានរង្វាន់ និងបណ្ណសរសើរទាំងនោះរួមមាន ពានរង្វាន់កន្លែងធ្វើការដ៏ល្អបំផុតនៅក្នុងតំបន់អាស៊ីឆ្នាំ២០២២ ពីHR Asia ពានរង្វាន់ឧត្តមភាពទំនួលខុសត្រូវសង្គមលើផ្នែកបរិស្ថាន ពីសភាពាណិជ្ជអាមេរិកនៅកម្ពុជា បណ្ណសរសើរលើកទឹកចិត្តមេត្រីភាពបរិស្ថានឆ្នាំ២០២២ ពីក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធកម្រិតអនុលោមភាពប្រភេទមាស ពីអគ្គនាយកដ្ឋានពន្ធដារ សារលិខិតថ្លែងអំណរគុណ និងការទទួលស្គាល់ជាសហគ្រាសបង់ពន្ធធំជាងគេលំដាប់ទី៨ ក្នុងឆ្នាំ២០២១ ពីសម្តេចនាយករដ្ឋមន្ត្រីកម្ពុជា និងបណ្ណសរសើរជាច្រើនទៀតដែលផ្តល់ដោយក្រសួង និងស្ថាប័នជាតិនៃព្រះរាជាណាចក្រកម្ពុជា។ យើងសូមគោរពកោតសរសើរដល់សហសេវិកទាំងអស់ ដែលបានចូលរួមចំណែកនាំយកភាពជោគជ័យទាំងនេះមកឱ្យក្រុមហ៊ុន។ ពានរង្វាន់ និងបណ្ណសរសើរទាំងនេះ មិនត្រឹមតែបានបន្ថែមនូវគុណតម្លៃក្នុងការរក្សាកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនយើងនៅក្នុងទីផ្សារប៉ុណ្ណោះទេ តែក៏ជាកម្លាំងជំរុញឱ្យយើងបន្តឆន្ទៈដឹកនាំប្រតិបត្តិការអាជីវកម្មតាមរបៀបដ៏ត្រឹមត្រូវ ដើម្បីការអភិវឌ្ឍឱ្យកាន់តែប្រសើរទាំងថ្ងៃនេះ និងថ្ងៃស្អែក។




# ខេមប្រ៊ូវ ឈ្នះពានរង្វាន់ផ្នែក ឧត្តមភាពGuinness League of Excellence F22

*Guinness League of Excellence F22*
*Beer Category*

*3rd Place Runner Up*

*Cambrew Cambodia*

*Guinness League of Excellence F22*
*Beer Category*

*Best Third Party Owned: Asia Pacific*

*Cambrew Cambodia*

សូមទះដៃអបអរសាទរដល់កិច្ចខិតខំរបស់ពួកយើងនៅខេមប្រ៊ូវ សម្រាប់ភាពជោគជ័យយ៉ាងធំធេងរបស់យើង គឺការទទួលបានពានរង្វាន់ Guinness League of Excellence F22 ពីមជ្ឈមណ្ឌលបច្ចេកទេសពាណិជ្ជសញ្ញា Guinness ដែលយើងទទួលបានចំណាត់ថ្នាក់លេខ៣នៅទូទាំងសកលលោក និងការទទួលស្គាល់ថាជាអ្នកផលិតស្រាបៀរ Guinness ល្អបំផុតមួយប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក។

The Guinness League of Excellence ជាពានរង្វាន់កំណត់ស្តង់ដារផលិតសម្រាប់ពាណិជ្ជសញ្ញា Guinness ដែលផលិតដោយរោងចក្រស្រាបៀរដែលខ្លួនមានកិច្ចសហប្រតិបត្តិការជាមួយនៅទូទាំងសាកលលោក។ ពានរង្វាន់នេះ រៀបចំឡើង ដើម្បីធានាពីស្តង់ដារខ្ពស់នៅក្នុងរោងចក្រផលិតស្រាបៀរ Guinness នៅក្រៅប្រទេសអៀរឡង់។ ការប្រកួតប្រជែងដ៏តឹងរ៉ឹងនេះ ត្រូវបានវាយតម្លៃយ៉ាងយកចិត្តទុកដាក់ដោយគណៈកម្មការវិនិច្ឆ័យឯករាជ្យមកពីមជ្ឈមណ្ឌលបច្ចេកទេសពាណិជ្ជសញ្ញា Guinness នៅទីក្រុងឌុប្លីន ប្រទេសអៀរឡង់។




ពានរង្វាន់នេះបានបញ្ជាក់ និងទទួលស្គាល់ថា ការផលិត និងការធ្វើប្រតិបត្តិការរបស់ខេមប្រ៊ូវលើពាណិជ្ជសញ្ញា Guinness មានស្តង់ដារគុណភាពខ្ពស់ ស្របទៅតាមការតម្រូវ និងទាមទាររបស់ពាណិជ្ជសញ្ញា Guinness។ ខេមប្រ៊ូវ នឹងបន្តរក្សានូវស្តង់ដារផលិតដែលមានគុណភាពខ្ពស់ជានិច្ច ដើម្បីបន្តផ្តល់ភាពឥតខ្ចោះរាល់ថ្ងៃជូនដល់អតិថិជន។
ការទទួលបានពានរង្វាន់ដ៏វិសេសវិសាលនេះ មិនមែនកើតមកពីភ័ព្វសំណាងនោះឡើយ ប៉ុន្តែជាលទ្ធផលដែលបានមកពីកិច្ចខិតខំប្រឹងប្រែង យ៉ាងយកចិត្តទុកដាក់ និងការតាំងចិត្តខ្ពស់របស់សហសេវិក ដើម្បីធានាពីគុណភាពផលិតខ្ពស់ទាំងរសជាតិ និងគុណភាពរបស់ស្រាបៀរ Guinness ។
សូមអរគុណដល់សហសេវិកទាំងអស់ សម្រាប់ការចូលរួម និងខិតខំប្រឹងប្រែងបំពេញតួនាទីដែលនាំឱ្យយើងសម្រេចបាននូវសមិទ្ធផលដ៏អស្ចារ្យនេះ។



# តបស្នងសហសេវិកដែលលេចធ្លោជាមួយនឹងការគោរពឱ្យតម្លៃ និងពានរង្វាន់កិត្តិយស

សហសេវិកដែលមានការខិតខំប្រឹងប្រែង ឧស្សាហ៍ព្យាយាម មានភាពច្នៃប្រឌិត និងចេះជួយយកឧស្សាហ៍មិត្តរួមការងារ នឹងមិនត្រូវបានមើលរំលងឡើយ។

អួន ស្រីទូច គឺជាសហសេវិកលេចធ្លោមួយរូបក្នុងការងារប្រចាំថ្ងៃរបស់គាត់ ក៏ដូចជានៅក្នុងការងារជាក្រុម។ ភាពឱហាតធ្វើការរបស់ស្រីទូច បានធ្វើឱ្យគាត់ ក៏ដូចជាខេមប្រ៊ូវទទួលបានពានរង្វាន់ Chairman’s Circle of Champions ដែលជាពានរង្វាន់កិត្តិយសដ៏មានតម្លៃមួយ ផ្តល់ដោយក្រុមហ៊ុន PepsiCo ។

តាមរយៈសារលិខិតរបស់លោក Ramon Laguarta ដែលជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន PepsiCo បានមានប្រសាសន៍ថា៖ «ពានរង្វាន់នេះ បានចាត់ទុកអ្នកជាបុគ្គលមួយរូបស្ថិត នៅក្នុងក្រុមឥស្សរជននៃរង្វង់ប្រតិបត្តិការសាកលរបស់ PepsiCo។ ជារៀងរាល់ឆ្នាំ មានតែបេក្ខជនមួយរូបប៉ុណ្ណោះក្នុងចំណោមបេក្ខជន១០រូប ដែលត្រូវបានជ្រើសរើសជាសមាជិកនៃ Chairman’s Circle of Champions។ នេះមានន័យថា អ្នកជាមនុស្សពូកែ នៅក្នុងចំណោមអ្នកពូកែៗ។ ហើយនេះជាជោគជ័យដ៏អស្ចារ្យមួយរបស់អ្នក និងក្រុមហ៊ុនរបស់អ្នក ហើយខ្ញុំជឿថា អ្នកពិតជាមានមោទកភាពយ៉ាងខ្លាំង។ អ្នកទទួលបានពាននេះ ដោយសារតែអ្នកបានខិតខំ និងមានការតាំងចិត្តខ្ពស់ ធ្វើឱ្យ PepsiCo មានភាពរស់រវើក និងធ្វើឱ្យអតិថិជន និងសហគមន៍ពោរពេញដោយស្នាមញញឹម »។




ក្នុងនាមជាប្រធានគ្រប់គ្រងផ្នែកខ្សែច្រវាក់ផលិតភេសជ្ជៈ ប្រចាំនៅរោងចក្រផលិតនៅខេត្តព្រះសីហនុ ស្រីទូច មានការខិតខំប្រឹងប្រែង និងឆ្លងកាត់ការលះបង់ជាច្រើនក្នុងការកសាងភាពលេចធ្លោរបស់ខ្លួននៅក្នុងការប្រកួតប្រជែងនេះ។ ស្រីទូច រកឃើញចំណុចរាំងស្ទះ និងបញ្ហាប្រឈមនានានៅក្នុងខ្សែច្រវាក់ផលិតកម្មទឹកក្រូច ដែលទិន្នន័យទាំងនោះ បានជួយឱ្យក្រុមការងារកែលម្អប្រព័ន្ធដំណើរការផលិតកម្មឱ្យដំណើរការកាន់តែមានស័ក្តិសិទ្ធភាព។ ស្រីទូច ក៏បានចូលរួមយ៉ាងសកម្មក្នុងការបង្កើតឱ្យមានបរិយាកាសការងារមានសុវត្ថិភាព តាមរយៈបង្កើតវគ្គបណ្តុះបណ្តាល ក៏ដូចជាបទបញ្ញាផ្ទៃក្នុងនានាក្នុងខ្សែច្រវាក់ផលិតកម្ម និងតែងតែដើរតួភាពជាគំរូ។ ស្រីទូច បានចូលរួមបង្កើនពិន្ទុសវនកម្មក្នុងខ្សែច្រវាក់ផលិតកម្មទឹកក្រូច រិះរកវិធីសាស្ត្រកាត់បន្ថយចំណាយ និងសន្សំធនធានដោយប្រើប្រាស់បច្ចេកវិទ្យាជំនួស ជាពិសេសក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ស្រីទូចបានរក្សាបរិមាណផលិតឆ្លើយតបនឹងតម្រូវការលក់បានយ៉ាងល្អ។ មិនត្រឹមតែជាអ្នកអនុវត្តការងារដ៏មានប្រសិទ្ធភាពម្នាក់ប៉ុណ្ណោះនោះទេ ស្រីទូច ក៏ជាអ្នកដឹកនាំដ៏ខ្លាំងមួយរូប ដែលជួយបណ្តុះបណ្តាល និងតម្រង់ផ្លូវសហសេវិកក្រោមបង្គាប់របស់ខ្លួនចំនួន ២រូប (ស្រីណុច និងប៊ុននី) ឱ្យក្លាយជាអ្នកជំនាញផ្នែកផលិតភេសជ្ជៈ។ លើសពីនេះ ស្រីទូច ក៏សកម្មក្នុងសកម្មភាពមនុស្សធម៌ កម្មវិធីបរិច្ចាគនានា ក៏ដូចជាមានជំនឿសាសនាដ៏ប្រពៃ និងដឹងគុណូបការៈជួយទំនុកបម្រុងក្រុមគ្រួសាររបស់គាត់។

ជារៀងរាល់ឆ្នាំ ពិធីអបអរ និងជួបជុំជ័យលាភីនៃ Chairman's Circle of Champions នេះ ត្រូវបានប្រារព្ធឡើងនៅទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិក ដោយអនុញ្ញាតឱ្យអ្នកទទួលជ័យលាភីអាចនាំមនុស្សសំខាន់ម្នាក់ទៅអមដំណើរជាមួយ ដោយរាល់ការចំណាយទាំងអស់ ត្រូវបានទទួលរ៉ាប់រងដោយក្រុមហ៊ុន PepsiCo ។ ប្រមាណជាពីរបីឆ្នាំចុងក្រោយនេះ ដោយសារវិបត្តកូវីដ-១៩ ពិធីប្រគល់ពានរង្វាន់ Chairman's Circle of Champions នេះ ត្រូវបានរៀបចំឡើងតាមប្រព័ន្ធអនឡាញ។ កាលពីថ្ងៃទី០៤ វិច្ឆិកា ស្រីទូច បានចូលរួមជាមួយសមាជិកលេចធ្លោដទៃផ្សេងទៀត និងបានស្តាប់សារសំខាន់ៗពីថ្នាក់ដឹកនាំក្រុមហ៊ុននានា ព្រមទាំងទទួលបានវត្ថុអនុស្សាវរីយ៍ជាច្រើនពីកម្មវិធីនេះ ដែលមានសំខាន់ៗដូចជា នាឡិកាអត្តសញ្ញាណនៃពាន Chairman's Circle of Champions មេដាយ និងផ្លាកកិត្តិយសជាដើម។

# តើសហសេវិកគំរូក្នុងការអនុវត្ត វប្បធម៌ 3A មានបុគ្គលិកលក្ខណៈដូចម្តេចខ្លះ?

វប្បធម៌ 3A រួមមានការស្របគ្នាតែមួយ ការទទួលខុសត្រូវ និងការអនុវត្ត គឺជាគំនិតគន្លឹះសម្រាប់សហសេវិកនៅខេមប្រ៊ូវអនុវត្តការងារ ព្រោះថាពួកគាត់ជាអ្នក ជំរុញការលើកទឹកចិត្ត និងបង្កើតបរិយាកាសការងារដែលពោរពេញដោយទំនួលខុសត្រូវ។ វប្បធម៌ A ទាំងបី ផ្តល់តម្លៃដល់សហសេវិកយើងក្នុងការអនុវត្តភាពជាគំរូ។



Sergey Rychkov គឺជាអ្នកដឹកនាំដ៏គំរូម្នាក់ ដែលគាត់ផ្តោតខ្ពស់លើលទ្ធផលការងារ ហើយតែងតែជួយគាំទ្រក្រុមការងារឆ្លើយតបរហ័ស និងយល់ពីសហការី។ ក្រៅពីជឿទុកចិត្តលើសហការី Sergey បើកចំហសម្រាប់ការពិភាក្សា និងទទួលយកមតិកែលម្អនានា។




អាកប្បកិរិយាវិជ្ជមាន និងការជួយជ្រោមជ្រែងជាទង្វើមួយដែល ឃួន សុភ័ក្រ តែងតែប្រកាន់យក និងផ្តល់ទៅឱ្យក្រុមការងាររបស់គាត់។ ភាពវិជ្ជមានរបស់ សុភ័ក្រ្ត បានផ្តល់ជាគំរូឧទាហរណ៍ជាក់ស្តែងដែលជាធាតុសំខាន់ៗនៅក្នុងវប្បធម៌ 3A ដូចជាមានការទទួលខុសត្រូវខ្ពស់ និងអនុវត្តការងារពោរពេញទៅដោយវិន័យ។



Franco Maria Maggi ជាអ្នកដឹកនាំមួយរូប ដែលផ្តល់ភាពសំខាន់ទៅលើក្បួនច្បាប់ និងកែលម្អប្រព័ន្ធការងារឱ្យកាន់តែមានដំណើរការត្រឹមត្រូវ។ ចំណុចខ្លាំងក្នុងការចរចា និងភាពត្រង់របស់គាត់ បានជួយឱ្យការអនុវត្តការងារក្រុមប្រព្រឹត្តទៅយ៉ាងរលូន ក៏ព្រោះថាគាត់ឱ្យតម្លៃសហការីទាំងអស់ស្មើៗគ្នា ក៏ដូចជាចែករំលែកចំណេះដឹងដែលខ្លួនគាត់មានទៅកាន់អ្នកនៅជុំវិញខ្លួន។



លី សូរភី តែងតែឱ្យតម្លៃខ្ពស់ទៅការអនុវត្តសកម្មភាព និងដំណោះស្រាយដើម្បីភាពជោគជ័យ។ គាត់មានចំណាត់ការ និងអនុវត្តការងារឆាប់រហ័ស ហើយមានទំនាក់ទំនងដ៏មានប្រសិទ្ធភាពជាមួយសហការី ដើម្បីជំរុញវប្បធម៌ស្របគ្នាតែមួយ និងបណ្តុះស្មារតីក្រុម។



ម៉ៅ សុធារិទ្ធ តែងតែធ្វើការជាមួយនឹងស្នាមញញឹម។ ភាពសកម្មក្នុងការអនុវត្តការងារ ការសហការ និងការបើកចិត្តទូលាយទទួលយកមតិរិះគន់ដើម្បីស្ថាបនា បានធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ដែលអនុវត្តគុណតម្លៃ 3A បានយ៉ាងល្អ។



Bruce Kidner ទទួលបានការស្រឡាញ់ចូលចិត្ត និងគោរពកោតសរសើរពីសហសេវិក ព្រោះគាត់តែងតែស្តាប់ និងទទួលយកយោបល់របស់សហការីមកពិចារណាជានិច្ច។ សហសេវិក បានសរសើរថា Bruce ជាអ្នកដឹកនាំពោរពេញដោយភាពក្លៀវក្លា និងអត់ធ្មត់។ គាត់ តែងតែបង្កលក្ខណៈងាយស្រួលដល់សហការីក្នុងការទំនាក់ទំនងជាមួយគាត់ ហើយគាត់តែងតែជួយគាំទ្រ ក៏ដូចជាផ្តល់យោបល់ល្អៗដល់សហសេវិក។

Serkan Bulut ជាអ្នកដែលមានការគិតពិចារណាជ្រៅជ្រះ ជាមួយនឹងចក្ខុវិស័យវែងឆ្ងាយ ហើយក៏អាចចាត់ទុកជាអ្នកជំនាញម្នាក់ផងដែរ។ គាត់ជាសហសេវិក មានការប្តេជ្ញាមួយរូប ដែលតែងតែស្វែងរកភាពស្របគ្នាតែមួយ និងការអនុវត្តសកម្មភាព។ Serkan ជាបុគ្គលម្នាក់ដែលងាយស្រួលក្នុងការប្រាស្រ័យទាក់ទងតែងតែផ្តល់ការជួយគាំទ្រដល់ក្រុមការងារ និងមិនកំណាញ់ក្នុងការចែករំលែកចំណេះដឹងទៅកាន់សហសេវិកនោះទេ។



ទាំងអស់នេះបានបង្ហាញថា ជារឿងដ៏សំខាន់ណាស់ដែលសហសេវិកទាំងអស់របស់ខេមប្រ៊ូវ អាចបណ្តុះភាពវិជ្ជមានរបស់ខ្លួន តាមរយៈវប្បធម៌ A ទាំងបី (ការស្របគ្នាតែមួយ ការទទួលខុសត្រូវ និងការអនុវត្តសកម្មភាព)។ សូមចាំថា ក្រុមការងារដែលល្អ ផ្តើមចេញពីឥរិយាបថដ៏ល្អប្រពៃរបស់យើងម្នាក់ៗ។

# ទិវាក្ដីស្រឡាញ់ឆ្នាំ២០២៣ ខេមប្រ៊ូវ កំណត់យកជាថ្ងៃបង្ហាញការយកចិត្តទុកដាក់ចំពោះសហសេវិក



ខេមប្រ៊ូវ បង្កើនភាពកាន់តែជិតស្និទ្ធជាមួយសហសេវិក ដោយបានកំណត់យក ទិវានៃក្ដីស្រឡាញ់ ដែលជាថ្ងៃនិមិត្តរូបតំណាងការយកចិត្តទុកដាក់ចំពោះសហសេវិក។
នៅរាជធានីភ្នំពេញ យើងបានជូនផ្កាដែលច្នៃពីសំបកពោត ស្លឹកឈើ និងស្លឹកចាក ដល់សហការី ដែលផ្កាទាំងនោះកែច្នៃដោយប្រជាសហគមន៍។ ចេតនាជ្រើសរើសយកផ្កា ប្រភេទនេះ គឺយើងមិនត្រឹមតែចង់បង្ហាញពីការយកចិត្តទុកដាក់ជាមួយសហសេវិកប៉ុណ្ណោះ ទេ តែក៏ជាសកម្មភាពមួយបង្ហាញពីការគាំទ្ររបស់ខេមប្រ៊ូវ ចំពោះផលិតកែច្នៃក្នុង សហគមន៍ និងនិងការយកចិត្តទុកដាក់ចំពោះសហគមន៍យើងផងដែរ។
រីឯនៅតាមបណ្ដាខេត្តវិញ យើងបាន ប្រារព្ធទិវានេះជាមួយនំខេក និងជូនបាច់ផ្កា ស្រស់ដល់សហសេវិក។ ពេលខ្លះ ទង្វើដ៏តូចសាមញ្ញ ក៏អាចបង្កើតនូវលទ្ធផលជាវិជ្ជមានដ៏ធំធេងផងដែរ។













# កាសស្បៀរ ប្រារព្ធទិវាក្តីស្រឡាញ់ ដោយផ្តល់ភាពរីករាយ ការចងចាំដ៏អស្ចារ្យដល់អតិថិជន






ខែកុម្ភៈ ជាខែនៃក្តីស្រលាញ់គ្រប់ទម្រង់។ ស្រាបៀរកាសស្បៀរ ក៏បានរៀបចំកម្មវិធី “Carlsberg Love Day” ដោយបានបង្កើតនូវកម្មវិធីពិសេសសម្រាប់អតិថិជន ដើម្បីអបអរទិវាក្តីស្រលាញ់ ដែលកម្មវិធីនេះបានរៀបចំធ្វើនៅ Eclipse Sky Bar និង AVENUE ចំថ្ងៃ១៤ កុម្ភៈ តែម្តង។

អតិថិជនរបស់កាសស្បៀរ បានចូលរួមសប្បាយរីករាយជាមួយកម្មវិធីនេះ ជាពិសេសមានការចូលរួម និងសម្តែងរបស់សិល្បករល្បីៗ។ កម្មវិធីនេះ បានក្លាយជារាត្រីនៃការចងចាំដ៏អស្ចារ្យ ដែលស្រាបៀរកាសស្បៀរ ផ្តល់ជូនអតិថិជន។



កាសស្បៀរ ទំនងជាស្រាបៀរដ៏ល្អបំផុតលំដាប់ពិភពលោក។

# កាសស្បែរ គ្រុប បន្តសម្រេចបានកំណើនអាជីវកម្ម យ៉ាងរឹងមាំ ទោះស្ថិតក្នុងស្ថានភាពប្រឈមដ៏ស្រួចស្រាល់




ថ្មីៗនេះ កាសស្បែរ គ្រុប បានចេញសេចក្តីថ្លែងការណ៍ហិរញ្ញវត្ថុ ដោយបានលើកឡើងពីការសម្រេចបាននូវកំណើនអាជីវកម្មដ៏ប្រសើរ ជាមួយនឹងលទ្ធផលហិរញ្ញវត្ថុយ៉ាងរឹងមាំក្នុងឆ្នាំ២០២២ ទោះស្ថិតក្នុងស្ថានភាពប្រឈមដ៏ស្រួចស្រាល់ក៏ដោយ។

លទ្ធផលនៃយុទ្ធសាស្ត្រ Sail'22 របស់យើង បានមកពីកិច្ចខិតខំប្រឹងប្រែងយ៉ាងក្លៀវក្លារបស់សហសេវិកគ្រប់រូបរបស់កាសស្បែរ គ្រុប រួមទាំងខេមប្ប្រ៊ូរផងដែរនោះ ហើយពួកយើងបានបន្តអនុវត្តយុទ្ធសាស្ត្រអាជីវកម្មយ៉ាងមុះមុតជាមួយនឹងមហិច្ឆតាជាក់លាក់។

បើតាមរបាយការណ៍ បរិមាណលក់ (organic volume) របស់កាសស្បែរ គ្រុប បានកើនឡើង ៥.៧% ជាមួយនឹងប្រាក់ចំណូល (organic revenue) មានការកើនឡើង ១៥.៦ % ហើយប្រាក់ចំណេញប្រតិបត្តិការ (organic operating profit) កើនឡើងរហូតដល់ទៅ ១២.២%។

ដោយមិនរាប់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសរុស្ស៊ី យើងសម្រេចបានប្រាក់ចំណេញសុទ្ធ (net profits)ជិត ១០ ប៊ីលាន Danish krone ដែលយើងមិនធ្លាប់មានពីមុនមក។ សូមចូលរួមអបអរសាទរ ចំពោះសមិទ្ធផលជាទីគាប់ប្រសើរនេះ។

យើងមានការអនុវត្តយ៉ាងល្អតាមយុទ្ធសាស្ត្រហិរញ្ញវត្ថុអាទិភាព និងគោលដៅចីរភាពនៃយុទ្ធសាស្ត្រ SAIL'22 ។ យើងកំពុងតម្រង់ឆ្ពោះទៅរកការចេញដំណើរនៃយុទ្ធសាស្ត្រ SAIL'27 និងកំពុងអនុវត្តគោលដៅចីរភាពថ្មីស្តីពីបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) - រួមគ្នាឆ្ពោះទៅកាន់ហេរ្សូ និងលើសពីនេះ (TTZAB)។

ឆ្នាំ២០២៣ ជាឆ្នាំដ៏ប្រឈមនៅក្នុងទីផ្សារ ដោយសារភាពមិនប្រាកដប្រជានៃរបត់សាកល។ ទស្សនវិស័យរបស់យើង គឺជំរុញឱ្យមានកំណើនប្រតិបត្តិការពីក្នុងរង្វង់ -៥% ទៅ +៥% ដោយបត់បែនទៅនឹងស្ថានភាពសាកល ដែលកំពុងមានភាពស្រពេចស្រពិល។ យ៉ាងណាមិញ យើងកំពុងស្ថិតនៅចំណុចដែលអាចគ្រប់គ្រងបាននូវកត្តានានាដែលអាចរារាំងដល់អាជីវកម្មនៅក្នុងឆ្នាំនេះ ហើយបន្តបោះជំហានទៅសម្រេចនូវមហិច្ឆតារយៈពេលវែងរបស់យើង គឺសុទ្ធសឹងជាគុណសម្បត្តិនៃយុទ្ធសាស្ត្រប្រកបដោយភាពរឹងមាំរបស់យើង ការត្រៀមរៀបចំទុកជាមុន និងសុខភាពហិរញ្ញវត្ថុដ៏ល្អប្រសើរ ដែលយើងបានខិតខំកែលម្អ និងអភិវឌ្ឍកាលពី ២-៣ឆ្នាំមុន។

ដើម្បីស្វែងយល់បន្ថែម សូមអានរបាយការណ៍ហិរញ្ញវត្ថុទាំងស្រុង និងសេចក្តីថ្លែងការណ៍ជាសាធារណៈនៅលើគេហទំព័រ Carlsberg Group។

ខេមប្រ៊ូវ ក៏ជាចំណែកមួយក្នុងការបង្កើតលទ្ធផលដ៏ប្រសើរនេះ។ តំណាងឱ្យ កាសស្បែរគ្រុប យើងសូមថ្លែងអំណរគុណចំពោះការចូលរួមយ៉ាងស្មោះស្ម័គ្ររបស់សហសេវិក និងដៃគូពាក់ព័ន្ធទាំងអស់ ដែលបានធ្វើឱ្យយើងបន្តសម្រេចបានជោគជ័យគួរជាទីមោទក។




# សកម្មភាពថ្មី គោលដៅថ្មី ជោគជ័យថ្មី

ក្នុងនាមជាបុត្រសម្ព័ន្ធមួយរបស់ កាសស្បឺរ គ្រុប ខេមប្រ៊ូវ មានក្តីសោមនស្ស ដែលបានចូលរួមចំណែកក្នុងការសម្រេចបាននូវរបាយការណ៍ស្តីពីបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ឆ្នាំ២០២២ដ៏ប្រសើរ។ របាយការណ៍នេះ បានបង្ហាញពីសមិទ្ធផលសំខាន់ៗ និងការបន្តវឌ្ឍនភាពឆ្ពោះទៅភាពកាន់តែប្រសើរនាពេលអនាគត។

របាយការណ៍ឆ្នាំនេះ រួមបញ្ចូលទាំងការសង្ខេបពីគោលដៅចីរភាពរួមគ្នាឆ្ពោះទៅកាន់ហ្សេរ៉ូ (TTZ) និងរួមគ្នាឆ្ពោះទៅហ្សេរ៉ូ និងលើសពីនេះ (TTZAB) ដែលមានមហិច្ឆតានាំយកលទ្ធផល និងដំណោះស្រាយសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមានកាន់តែច្រើន សម្រាប់ឆ្នាំ២០៣០ និងឆ្នាំ២០៤០។

ចាប់តាំងពីការបង្កើតឡើងក្នុងឆ្នាំ២០១៧ គោលដៅចីរភាព TTZ បានកំណត់ នូវវឌ្ឍនភាពដ៏ប្រសើរដែលនាំភាពវិជ្ជមាននៅក្នុងគោលដៅចីរភាពរបស់យើង ដូចជាមហិច្ឆតាគ្មានការបញ្ចេញឧស្ម័នកាបូនិច គ្មានការខ្ជះខ្ជាយទឹក គ្មានការពិសាគ្រឿងស្រវឹងដោយគ្មានការទទួលខុសត្រូវ និងគ្មានវប្បធម៌គ្រោះថ្នាក់។












នៅចុងឆ្នាំ២០២២ TTZAB បានពង្រីកវិសាលភាពដោយផ្តោតការយកចិត្តទុកដាក់របស់ខ្លួនទៅលើវិស័យចំនួន ១១បន្ថែមទៀត ដើម្បីជួយដោះស្រាយបញ្ហាប្រឈមជាសកលលើផ្នែកសង្គម និងបរិស្ថាន។

Cees ‘t Hart អគ្គនាយកប្រតិបត្តិរបស់កាសស្បឺរ គ្រុប មានប្រសាសន៍នៅក្នុងរបាយការណ៍នេះថា ការរួមគ្នាធ្វើឱ្យកាន់តែប្រសើរទាំងនៅថ្ងៃនេះនិងថ្ងៃស្អែក ស្តាប់ទៅហាក់ដូចជាសាមញ្ញ និងងាយស្រួល។ ប៉ុន្តែបើយើងគិតនិងពិចារណាឱ្យស៊ីជម្រៅ នោះយើងនឹងឃើញថា កិច្ចការដ៏មហិមានេះ ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការដែលមានភាពស្មុគស្មាញ ជាមួយដៃគូពាក់ព័ន្ធ ក្នុងការបង្កើតដំណោះស្រាយ អនុលោមតាមកិច្ចការពារបរិស្ថាន ការអភិវឌ្ឍសង្គម បរិបទទីផ្សារ ការរីកចម្រើននៃបច្ចេកវិទ្យា បូរណភាពទឹកដី និងកត្តាជាច្រើនទៀត។

ជាមួយនឹងជោគជ័យរបស់ TTZ ដែលមានស្រាប់របស់យើង TTZAB នឹងក្លាយជាជំហានជោគជ័យថ្មីមួយទៀតសម្រាប់ក្រុមហ៊ុន ក្នុងការសម្រួច និងរំលេចខ្លួនឱ្យក្លាយជាអ្នកផលិតស្រាបៀរដ៏មានទំនួលខុសត្រូវ និងបង្កើតអនាគតរួមគ្នាដ៏ប្រសើរសម្រាប់ថ្ងៃនេះ និងថ្ងៃស្អែក។

ស្វែងយល់បន្ថែមអំពីរបាយការណ៍ ESG សូមចូលទៅកាន់គេហទំព័ររបស់ Carlsberg Group។

# ខេមប្រ៊ូវ បន្តលើកតម្កើងវប្បធម៌គោរព និងផ្តល់តម្លៃគ្នា



What is sexual harassment?



What should I do?



The impact of sexual harassment



Preventing sexual harassment



Speaking up: Reporting sexual harassment



Follow-up investigations

សហសេវិក ខេមប្រ៊ូវ បានទទួលការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីការបញ្ចៀសការបៀតបៀនផ្លូវភេទ និងការរក្សានូវឥរិយាបថគោរពគ្នាទាំងនៅកន្លែងធ្វើការ និងក្រៅម៉ោងធ្វើការ។ វគ្គបណ្តុះបណ្តាលនេះធ្វើឡើងជារៀងរាល់ឆ្នាំដែលតម្រូវដោយកាសស្បឺរ គ្រុប ហើយក៏ជាផ្នែកមួយនៃរបៀបវារៈ ពិពិធភាព សមធម៌  និងបរិយាប័ន្ន (DE&I) របស់យើង។

ក្នុងនាមជាក្រុមហ៊ុនផលិតស្រាបៀរដែលមានទំនួលខុសត្រូវជាសកល  យើងតាំងចិត្តយ៉ាងមុតមាំនៅក្នុងការយកចិត្តទុកដាក់ចំពោះសហសេវិករបស់យើងដោយសេចក្តីថ្លៃថ្នូរ និងការគោរព ព្រមទាំងលើកកម្ពស់ការផ្តល់ឱកាសស្មើគ្នា។ យើងចង់ឱ្យសហសេវិកគ្រប់រូប ទទួលបានបរិយាកាសការងារដ៏រីករាយ និងមានសុវត្ថិភាព។

នៅកាសស្បឺរ គ្រុប យើងមិនអត់ឱនចំពោះការបៀតបៀនគ្រប់ទម្រង់ ទាំងនៅខាងក្នុង និងក្រៅកន្លែងធ្វើការ។ វគ្គបណ្តុះបណ្តាលនេះ នឹងជួយចង្អុលបង្ហាញសហសេវិក ឱ្យស្គាល់ពីឥរិយាបថមួយចំនួនដែលចាត់ទុកជាសកម្មភាពបៀតបៀន។ ហើយសហសេវិកកាន់តែយល់ច្បាស់ពីគោលការណ៍បញ្ចៀសកុំឱ្យមានការបៀតបៀន និងប្រុងប្រយ័ត្នខ្ពស់នូវសកម្មភាពដែលអាចនាំឱ្យមានការសន្និដ្ឋានថាជាទង្វើបៀតបៀន។



នៅក្នុងវគ្គបណ្តុះបណ្តាលនេះ សហសេវិកយើងក៏បានដឹងពីការអនុវត្តសកម្មភាពយ៉ាងត្រឹមត្រូវ ដើម្បីរក្សានូវវប្បធម៌គោរពគ្នា និងពីរបៀបឆ្លើយតប និងការរាយការណ៍នៅពេលមានទង្វើបៀតបៀន។ លើសពីនេះវគ្គបណ្តុះបណ្តាលនេះ ក៏នឹងពន្យល់សហសេវិកអំពីអ្វីទៅជាការព្រមព្រៀង និងសារសំខាន់នៃការព្រមព្រៀងគ្នានេះ។

សារសំខាន់ៗក្នុងវគ្គបណ្តុះបណ្តាលនេះ គឺការទទួលស្គាល់ថាការបៀតបៀនពិតជាអាចកើតមាន និងបង្កើតជាបញ្ហាធ្ងន់ធ្ងរទៀតផង។ សហសេវិក ត្រូវតែស្វែងយល់ និងមានការប្រុងប្រយ័ត្នខ្ពស់ អំពីការគិតរបស់អ្នកដទៃ  និងសង្កេតមើលពីការឆ្លើយតបរបស់គេចំពោះអ្វីដែលអ្នកបានធ្វើ និងបាននិយាយ ហើយអ្នកមិនត្រូវមានកាយវិការណាមួយដែលជាការមើលងាយ និងគំរាមកំហែងឡើយ។ ត្រូវនិយាយជាមួយជនរងគ្រោះ ឬរាយការណ៍ទៅផ្នែកធនធានមនុស្ស ឬផ្នែកច្បាប់ ប្រសិនបើអ្នកបានឃើញពីទង្វើបៀនបៀនផ្លូវភេទណាមួយបានកើតឡើង។ សូមកុំព្រងើយកន្តើយឱ្យសោះ។ ទន្ទឹមនឹងនេះ យើងក៏រួមគ្នាលើកទឹកចិត្តឱ្យមានការរាយការណ៍ពីទង្វើបៀតបៀន និងការពារពីការសងសឹកចំពោះអ្នកដែលបានរាយការណ៍។

# ចំណេះដឹងផ្នែកហរិញ្ញវត្ថុមានភាពសំខាន់សម្រាប់សហសេវិកគ្រប់ផ្នែក







ការបណ្តុះបណ្តាល និងបង្កើនចំណេះដឹងដល់សហសេវិក គឺជាសកម្មភាពដែលខេមប្រ៊ូវ បាន និងកំពុងយកចិត្តទុកដាក់ និងអនុវត្តយ៉ាងសកម្ម ដើម្បីបន្ថែមគុណតម្លៃ និងពង្រីកសក្តានុពលរបស់សហសេវិករបស់យើង។ ក្នុងចំណោមការបណ្តុះបណ្តាលជាច្រើន ការបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុ ទៅដល់សហសេវិកដែលមិនមានគ្រឹះផ្នែកហិរញ្ញវត្ថុ គឺជាអ្វីដែលយើងបានធ្វើ ក្នុងបំណងឱ្យសហសេវិកយើងយល់ដឹងពីមូលដ្ឋានគ្រឹះហិរញ្ញវត្ថុ ពាក្យគន្លឹះ និងនីតិវិធីនានានៅក្នុងផ្នែកនេះ ក៏ដូចជារបៀបកត់ត្រារបាយការណ៍ហិរញ្ញវត្ថុតាមផ្នែករបស់ខ្លួនឱ្យត្រឹមត្រូវ និងប្រតិបត្តិការទូទាត់នានាជាដើម។

វគ្គបណ្តុះបណ្តាលនេះ ក៏នឹងអនុញ្ញាតឱ្យសហសេវិក យល់ដឹងបន្ថែមអំពីលំហូរនៃរបាយការណ៍ហិរញ្ញវត្ថុ ដូចជារបាយការណ៍ប្រាក់ចំណេញ ខាតបង់ និងរបាយការណ៍តុល្យការជាដើម។ លើសពីនេះ សហសេវិកផ្នែកហិរញ្ញវត្ថុក៏នឹងផ្តល់នូវគន្លឹះតិចនិកពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុ ការស្វែងរកនូវឫសគល់នៃបញ្ហា និងចំណុចដែលមានចន្លោះប្រហោងនៅក្នុងរបាយការណ៍ដល់សហសេវិករបស់យើងផងដែរ។




ខេមប្រ៊ូវ នឹងធ្វើគ្រប់សកម្មភាពតាមដែលអាចធ្វើទៅបាន ដើម្បីពង្រីក និងបង្កើនចំណេះពិសោធន៍ក្នុងការងារដល់សហសេវិកគ្រប់រូប ក្នុងការជួយឱ្យពួកគេមានចំណេះដឹងទូលំទូលាយ និងការអនុវត្តការងាររបស់ពួកគេកាន់តែមានភាពងាយស្រួល និងមានប្រសិទ្ធភាព។

# កម្មវិធី CARLSBERG ASIA GRADUATE TRAINEE PROGRAM – CAMBODIA ឆ្នាំ២០២៣ ចាប់ផ្តើមបើកទទួលពាក្យហើយ!




ខេមប្រ៊ូវ ជាបុត្រសម្ព័ន្ធមួយរបស់កាសស្បៀរ គ្រុប នឹងជួយផ្តល់ដំណោះស្រាយក្នុងការផ្លាស់ប្តូរជីវិតការងាររបស់យុវជនដែលមានឆន្ទៈ និងមហិច្ឆតា ដោយការជួយអភិវឌ្ឍសមត្ថភាពជំនាញរបស់ពួកគេ និងអាចចាប់យកអាជីពការងារក្នុងក្តីស្រមៃតាមរយៈកម្មវិធី Carlsberg Asia Graduate Trainee Program។ កម្មវិធីអភិវឌ្ឍសមត្ថភាពយុវជនមួយនេះ មានរយៈពេល២ឆ្នាំ ដែលបង្កើតឡើងដោយកាសស្បៀរ គ្រុប ក្នុងគោលបំណងផ្តល់ឱកាសដល់យុវជនដែលទើបបញ្ចប់ការសិក្សា ឬមិនធ្លាប់មានបទពិសោធន៍សោះ ក្នុងការដុសខាត់សមត្ថភាព ក៏ដូចជាទទួលបានបទពិសោធន៍ការងារជាក់ស្តែងនៅក្នុងប្រព័ន្ធកាសស្បៀរ ដើម្បីឈានដល់ការចាប់យកអាជីពការងារក្នុងក្តីស្រមៃរបស់ពួកគេ ក៏ដូចជាដើម្បីអាចក្លាយជាអ្នកដឹកនាំនៅកាសស្បៀរនាពេលអនាគត។

រហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ កម្មវិធីនេះ កំពុងបើកជ្រើសរើសបេក្ខភាពជំនាន់ទី ២ ចំនួន ៥រូប ដែលនឹងត្រូវបណ្តុះសមត្ថភាពនៅក្នុងផ្នែកព័ត៌មានវិទ្យា ផ្នែកហិរញ្ញវត្ថុ ផ្នែកទីផ្សារ ផ្នែកលក់ និងផ្នែកខ្សែច្រវាក់ផ្គត់ផ្គង់។ បេក្ខជនដែលត្រូវបានជ្រើសរើស នឹងទទួលបានឱកាសប្តូរវេនធ្វើការយកបទពិសោធន៍នៅក្នុងផ្នែកផ្សេងៗនៅខេមប្រ៊ូវ ។

នៅខេមប្រ៊ូវ យើងនឹងបន្តវិនិយោគឥតឈប់ឈរក្នុងការអភិវឌ្ឍធនធានមនុស្ស ដែលជាចំណែកមួយនៃការចូលរួមអភិវឌ្ឍសង្គមឱ្យកាន់តែប្រសើរទាំងថ្ងៃនេះ និងថ្ងៃស្អែក។

CAMBREW LTD
Part of the Carlsberg Group

# គ្មានវប្បធម៌
# គ្រោះថ្នាក់


No. 1881, Russian Boulevard, Phum Ta gnoun, Sangkat Kakab, Khan Posenchey, Phnom Penh, Kingdom of Cambodia

+855 (0) 16 880 695

info.kh@carlsberg.asia

Cambrew Ltd

Cambrewltd

Cambrew Ltd

Carlsberg Group
Carlsberg Cambodia